**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# កិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍អង្កេតថ្នាក់ជាតិ
# ស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៦-២០១៧

សណ្ឋាគារសាន់វ៉េ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩

- *សូមគោរពគណៈអធិបតី*
- *លោកស្រីវេជ្ជ. Khin Cho Win Htin ទីប្រឹក្សាព័ត៌មានយុទ្ធសាស្ត្រ UNAIDS*
- *លោកវេជ្ជបណ្ឌិត ឡាន វណ្ណសេង អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ*
- *លោក Yann Derrennic នាយកប្រតិបត្តិអង្គការ Health Policy Plus*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីរាប់អាន*

ថ្ងៃនេះ ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ ជាភ្ញៀវជាតិ និងអន្តរជាតិ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍អង្កេតថ្នាក់ជាតិស្តីពីការចំណាយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា សម្រាប់ឆ្នាំ២០១៦-២០១៧ ដ៏មានសារៈសំខាន់នេះ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ!***

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនថា របាយការណ៍អង្កេតថ្នាក់ជាតិស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ បានពិពណ៌នាពីលំហូរធនធានដែលបានចំណាយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ពី ប្រភពដើមធនធានដល់ប្រជាជនដែលទទួលបានអត្ថប្រយោជន៍

ពីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍។ របាយការណ៍នេះនឹងជួយថ្នាក់ដឹកនាំឱ្យធ្វើការសម្រេចចិត្តដោយឈរលើព័ត៌មានយុទ្ធសាស្ត្រ និងអនុញ្ញាតឱ្យប្រទេសកម្ពុជាប្រមូលធនធានប្រកបដោយគណនេយ្យភាពកាន់តែខ្លាំង និងអនុវត្តកម្មវិធីកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលជាងមុន។ របាយការណ៍នេះជាឧបករណ៍មួយនៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ជាតិ និងក៏ជាឧបករណ៍សម្រាប់វាស់ស្ទង់និងតាមដានការចំណាយមេរោគអេដស៍នៅទូទាំងប្រទេស ដើម្បីធ្វើរបាយការណ៍ជូនស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ និងក្នុងកម្មវិធីអង្គការសហប្រជាជាតិផងដែរ។

បទបង្ហាញរបាយការណ៍អង្កេតថ្នាក់ជាតិស្តីពី ការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នឹងជម្រាបជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីថា ១) តើមានភាគីណាខ្លះដែលផ្តល់ហិរញ្ញប្បទាន? ២) តើមានភាគីណាខ្លះដែលគ្រប់គ្រងធនធាន? ៣) តើស្ថាប័នណាខ្លះដែលផ្តល់សេវា? ៤) តើកម្មវិធីអេដស៍មានសកម្មភាពអ្វីខ្លះ ហើយតើសកម្មភាពនីមួយៗចំណាយថវិកាអស់ប៉ុន្មាន? និង៥) តើអ្នកណាខ្លះបានទទួលអត្ថប្រយោជន៍ពីកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍?

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ!***

ក្នុងរយៈពេលជាង២៧ឆ្នាំកន្លងទៅ យើងបានធ្វើការកៀរគរធនធានថវិកាប្រមាណ៨៦០លានដុល្លារអាម៉េរិក សម្រាប់ការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ ជាលទ្ធផល យើងបានបញ្ចៀសមនុស្សប្រមាណ១លាននាក់ពីការឆ្លងមេរោគអេដស៍ និងបានបញ្ចៀសមនុស្សជាង៦សែននាក់ពីការស្លាប់ដោយសារជំងឺអេដស៍។ របាយការណ៍ការអង្កេតថ្នាក់ជាតិស្តីពីការចំណាយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦នេះ សំដៅត្រួតពិនិត្យការវិនិយោគ ធនធានលើការងារអេដស៍ ក្នុងអំឡុងឆ្នាំ២០១៦ និងឆ្នាំ២០១៧។

បើទោះបីជាប្រទេសកម្ពុជាយើងត្រូវបានទទួលស្គាល់ជាអន្តរជាតិថា បានសម្រេចនូវគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០១៧(មុនកាលកំណត់ឆ្នាំ២០២០)ក្តី ប៉ុន្តែការឈានទៅសម្រេចគោលដៅក្នុងការបញ្ចប់អេដស៍នៅឆ្នាំ២០២៥ នាពេលខាងមុខមិនមែនជាការងាយស្រួល និងសាមញ្ញពេកទេ។ ក្រៅពីមានផែនការយុទ្ធសាស្ត្រច្បាស់លាស់ គោលនយោបាយអំណោយផល បរិយាកាសគាំទ្រ និងធនធានមនុស្សប្រកបដោយបទពិសោធន៍ យើងក៏នៅត្រូវការចាំបាច់នូវថវិកាគ្រប់គ្រាន់ ទាន់ពេលវេលាសម្រាប់កិច្ចអន្តរាគមន៍របស់យើងផងដែរ។

ក្នុងរបាយការណ៍នេះបានបង្ហាញថា កញ្ចប់ថវិកាសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះមាននិន្នាការថយចុះគួរឱ្យកត់សម្គាល់ ជាពិសេសថវិកាពីដៃគូអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះ ថវិកាជាតិមាននិន្នាការកើនឡើងបន្តិចម្តងៗ តែមិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទេ។ ជាការពិត នៅក្នុងដំណាក់កាលនៃការបញ្ចប់អេដស៍នេះ កម្ពុជានៅតែត្រូវការជំនួយជាចាំបាច់ ពីដៃគូអភិវឌ្ឍន៍នៅឡើយ បើទោះបីជារាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបង្កើនថវិកាជាតិដើម្បីបំពេញគម្លាត និងតម្រូវការរបស់យើងក៏ដោយ។

កន្លងមក ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ប្រទេសកម្ពុជាយើង ទទួលបានជោគជ័យគួរជាទីមោទនៈគឺអាស្រ័យដោយសរសរស្តម្ភចំនួន៣ ៖

**ទី១) ភាពជាអ្នកដឹកនាំ** ÷ ការប្តេជ្ញាចិត្តដោយឈរលើគោលការណ៍ជាតិ និងអន្តរជាតិ។ ក្នុងនោះរួមមានគោលការណ៍ **បី-មួយ** (មានស្ថាប័នដឹកនាំសម្របសម្រួលតែមួយ មានផែនការយុទ្ធសាស្ត្រជាតិតែមួយ និងមានប្រព័ន្ធត្រួតពិនិត្យវាយតម្លៃតែមួយ)។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានយកចិត្តទុកដាក់ជាទីបំផុត ដោយបានប្រគល់ភារកិច្ចជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាអ្នកដឹកនាំផ្ទាល់។ ទស្សនវិស័យនៃផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ អាចអនុវត្តទៅបាន ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ គឺអាស្រ័យដោយការប្តេជ្ញាចិត្តខ្ពស់របស់ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាប្រតិបត្តិករនៅគ្រប់វិស័យ និងទីកន្លែងដែលនឹងធ្វើឱ្យមានការប្រែប្រួលនូវសូចនាករគន្លឹះនៃការងារអេដស៍។ នៅក្នុងបរិបទនៃការថយចុះជំនួយពីខាងក្រៅនេះ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់អាចចាត់ទុកបានថា ជាកត្តាចម្បងបំផុតដែលធានាថា យើងអាចសម្រេចគោលដៅ៩៥-៩៥-៩៥ និងបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០២៥ប្រាកដពិតមែន។

**ទី២) ភាពជាដៃគូ** ÷ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមប្រជាជនគន្លឹះ បាននិងកំពុងធ្វើការរួមគ្នាឆ្លើយតបជាពហុវិស័យដែលជាគន្លឹះជោគជ័យរបស់យើង។ ក្នុងឆ្នាំ២០១៩នេះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានបង្កើតក្រុមការងារលើកកម្ពស់សកម្មភាពឥស្សរជនឆ្នើមថ្នាក់ជាតិ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលឆ្ពោះទៅបញ្ចប់អេដស៍ នៅឆ្នាំ២០២៥ ជាពិសេសលុបបំបាត់ការចម្លងមេរោគអេដស៍ និង ស្វាយពីម្តាយទៅកូន។

ការវាយតម្លៃការចំណាយលើជំងឺអេដស៍ជាតិ មានគោលបំណងជួយក្រុមប្រឹក្សាជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅក្រសួងសុខាភិបាល ដើម្បីត្រួតពិនិត្យធនធានដែលខ្វះខាតទាំងនេះសម្រាប់មេរោគអេដស៍ និងជំងឺអេដស៍ដោយមិនត្រឹមតែគិតពីសមាសធាតុពីវិស័យសុខាភិបាលប៉ុណ្ណោះទេ ប៉ុន្តែគិតទាំងវិស័យផ្សេងទៀតដូចជា សេវាគាំពារសង្គម និងការបង្កបរិយាកាសគាំទ្រដែលជាការឆ្លើយតបពហុវិស័យទៅនឹងជំងឺអេដស៍ផងដែរ។

ក្នុងបរិបទនេះ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីថា សេចក្តីជូនដំណឹងលេខ ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បានដាក់ចេញវិធានការ ៦ចំណុចទាក់ទងនឹងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។ លើសពីនេះទៅទៀត កាលពីថ្ងៃទី២ ខែធ្នូកន្លងទៅថ្មីៗនេះ រាជធានីនិងខេត្តគោលដៅសំខាន់ចំនួន៤រួមមាន រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ បានចុះហត្ថលេខាជាមួយកម្មវិធីរួមអង្គការសហប្រជាជាតិឆ្លើយតប

នឹងមេរោគអេដស៍ និងជំងឺអេដស៍ (UNAIDS) លើគម្រោងទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (Fast-Track Cities Initiative) ក្នុងគោលបំណងសម្រេចការប្តេជ្ញាចិត្តរបស់យើង។ ដូច្នេះ ការវាយតម្លៃការចំណាយលើជំងឺអេដស៍នៅពេលអនាគតនឹងមានតួលេខបង្ហាញពី ភាពជាដៃគូនៃវិស័យនានាក្នុងទម្រង់ជាថវិកាជាក់ស្តែងឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។

**ទី៣) ការវិនិយោគ ÷** ការវិនិយោគក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់យើងបានចាប់ផ្តើមទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ និងពហុវិស័យ រហូតដល់ពេលបច្ចុប្បន្ន ដែលជាដំណាក់កាលអន្តរកាល ឈានទៅរកភាពជាម្ចាស់ប្រទេសនៃការឆ្លើយតបប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់។ នៅក្នុងការវិនិយោគរបស់យើងគឺចាប់ពីឆ្នាំ២០១៥មក រាជរដ្ឋាភិបាលបានចាប់ផ្តើមផ្តល់ថវិកាបន្ថែមចំនួន ១លាន ទៅ១,៥លានដុល្លារអាម៉េរិក សម្រាប់ទិញឱសថប្រឆាំងមេរោគ អេដស៍ និង៧សែនដុល្លារអាម៉េរិកក្នុងមួយឆ្នាំដែលជាថវិកាបដិភាគក្នុងគម្រោងមូលនិធិសកល។ ការវាយតម្លៃការចំណាយលើជំងឺអេដស៍ក្នុងឆ្នាំ២០១៧បញ្ជាក់ថា ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលមានត្រឹមតែ២៤%ប៉ុណ្ណោះ។ ប៉ុន្តែសូចនាកររួមគ្នារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បានព្រមព្រៀងគ្នានិងកំណត់ថា ថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនឹងកើនឡើងរហូតដល់៥០% នៅក្នុងឆ្នាំ២០២៣ខាងមុខនេះ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ!***

ការយល់ដឹងបានច្បាស់លាស់អំពីការចំណាយជាក់ស្តែង ក្នុងការឆ្លើយតបនឹងការងារអេដស៍នៅទូទាំងប្រទេសនេះអាចជួយជំរុញបាននូវតម្លាភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងគណនេយ្យភាពសម្រាប់រាជរដ្ឋាភិបាលកម្ពុជា សាធារណជន ដៃគូអភិវឌ្ឍន៍ និងអ្នកទទួលផលផងដែរ។ របាយការណ៍នេះក៏បានបង្ហាញឱ្យឃើញពី ការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ ក្នុងការផ្តល់ប្រភពធនធាន សម្រាប់ការសម្របសម្រួល និងអនុវត្តន៍កម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ផងដែរ។

ជាមួយគ្នានេះ ខ្ញុំសូមបញ្ជាក់ថា ព័ត៌មានទាំងអស់នៅក្នុងរបាយការណ៍នេះនឹងត្រូវយកទៅប្រើប្រាស់ក្នុងការប៉ាន់ប្រមាណថវិកាសម្រាប់ការអនុវត្តផែនយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ក៏ដូចជាគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ផងដែរ។

ខ្ញុំសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អន្តរជាតិ និងសប្បុរសជន បន្តចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយប្រើប្រាស់ថវិកាដែលមានឱ្យបានចំគោលដៅយុទ្ធសាស្រ្ត ដើម្បីពង្រឹងគុណភាពសេវា និងអនុវត្តកម្មវិធីឱ្យមានលក្ខណៈស៊ីណែស៊ី (synergy) ទាំងក្នុងប្រព័ន្ធសេវាសាធារណៈ និងទាំងក្នុងការថែទាំសុខភាពសហគមន៍។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ កម្មវិធីរួមអង្គការសហប្រជាជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ (UNAIDS) ទីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងអង្គការ Health Policy Plus ដែលបានជួយគាំទ្រទាំងបច្ចេកទេស និងថវិកាដល់ការងារនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុងការផ្តល់ព័ត៌មានស្តីពីថវិកាចំណាយសម្រាប់ឆ្នាំ២០១៦ និង២០១៧។ ជាពិសេស សូមថ្លែងអំណរគុណចំពោះក្រុមការងារថ្នាក់ជាតិស្តីពីការអង្កេតការចំណាយលើការងារឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ លើកទី៦នេះ ដែលមានមន្ត្រីពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ស្ថាប័នជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងក្រុមប្រជាជនគន្លឹះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជោគជ័យថ្មីៗបន្តទៀតក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងសូមប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនូវ “**របាយការណ៍ស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៦-២០១៧**” ចាប់ពីពេលនេះតទៅ។

សូមអរគុណ!